ក្នុងនោះ គ.ជ.ប បានសម្រេចយល់ព្រមជាផ្លូវការចំនួន ១៣ គណបក្ស ដែលមានបេក្ខជនពេញសិទ្ធិសរុប ១.២២២ រូប (ស្ត្រី ៣៥៦ រូប) និងបេក្ខជនបម្រុងសរុប ១.៣៧២រូប(ស្ត្រី ៤៨១រូប)។បច្ចុប្បន្ន គ.ជ.ប បាននិងកំពុងដំណើរការពិនិត្យឯកសារ និងលក្ខខណ្ឌចុះបញ្ជីរបស់គណបក្សនយោបាយមួយចំនួនទៀត ស្របតាមការកំណត់នៃច្បាប់ស្តីពីការបោះឆ្នោត។

ទី៣- ដំណាក់កាលឃោសនាបោះឆ្នោត ដែលមានរយៈពេល ២១ ថ្ងៃ គិតចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣។

ទី៤- ដំណាក់កាលបោះឆ្នោត រាប់សន្លឹកឆ្នោត និងប្រកាសលទ្ធផលនៃការបោះឆ្នោត។

ឯកឧត្តមបានមានប្រសាសន៍ថា គ្រប់ដំណាក់កាលនីមួយៗ អាចប្រព្រឹត្តទៅបានដោយជោគជ័យ មានសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ល្អ គឺអាស្រ័យដោយមានកិច្ចសហការពីយន្តការ រចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ជាពិសេសលេខាធិការដ្ឋាននៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត និងការអនុវត្តតួនាទី និងភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់របស់គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍រាជធានី ខេត្តសម្រាប់ការបោះឆ្នោត អាជ្ញាធរដែនដី កងកម្លាំងមានសមត្ថកិច្ច និងភ្នាក់ងារសន្តិសុខបោះឆ្នោតទាំងអស់។ ហេតុដូច្នេះហើយ ដើម្បីធានាប្រសិទ្ធភាពការងារនេះ ទើបតម្រូវឱ្យកម្លាំងមានសមត្ថកិច្ច និងភ្នាក់ងារសន្តិសុខបោះឆ្នោត មានការយល់ដឹងបានល្អ ច្បាស់លាស់អំពីច្បាប់ស្តីពីការបោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងក្រមសីលធម៌សម្រាប់ភ្នាក់ងារសន្តិសុខបោះឆ្នោត។

ឯកឧត្តម **ទេព នីថា** បានលើកឡើងទៀតថា វគ្គបណ្តុះបណ្តាលលើកនេះមានលក្ខណៈពិសេស និងខុសប្លែកពីវគ្គបណ្តុះបណ្តាលមុនៗ ដោយលើកនេះ លេខាធិការដ្ឋាននៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត និង គ.ជ.ប បានសហការគ្នារៀបចំធ្វើការបណ្តុះបណ្តាលដល់គ្រូបង្គោល និងភ្នាក់ងារសន្តិសុខបោះឆ្នោត ក្នុងជួរយន្តការរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតនៅថ្នាក់ជាតិ និងរាជធានី ខេត្ត ដើម្បីបន្តបណ្តុះបណ្តាលនៅតាមអង្គភាពពាក់ព័ន្ធ និងនៅតាមមូលដ្ឋាននៃរាជធានី ខេត្តនីមួយៗរៀងៗខ្លួន។

ឯកឧត្តមអគ្គលេខាធិការ គ.ជ.ប សង្ឃឹមយ៉ាងមុតមាំថា សិក្ខាកាមទាំងអស់នឹងទទួលបាននូវចំណេះដឹង ព្រមទាំងបទពិសោធន៍ថ្មីៗបន្ថែមទៀត ដើម្បីយកទៅអនុវត្តសម្រាប់យុទ្ធនាការការពារដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នេះ ឱ្យមានប្រសិទ្ធភាព និងទទួលបាននូវលទ្ធផលល្អប្រសើរ ក្នុងបរិយាកាសស្ងប់ស្ងាត់ មានសន្តិសុខ សុវត្ថិភាព គ្មានការបំភិតបំភ័យ គ្មានអំពើហិង្សា និងគ្មានការគំរាមកំហែង។

សូមជម្រាបជូនថា វគ្គបណ្តុះបណ្តាលនេះ មានសិក្ខាកាមចូលរួមជាគ្រូបង្គោលនៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត មកពី ២៥ រាជធានី ខេត្ត និងមន្ត្រីបោះឆ្នោតនៃទីស្តីការ គ.ជ.ប សរុបប្រមាណ ១៨០ នាក់។



អគារ គ.ជ.ប៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ៖ 012 959 666 / 092 105 556 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីម៉ែល៖ info@nec.gov.kh